ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អគ្គនាយកដ្ឋានអប់រំ
នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

# របាយការណ៍សង្ខេបស្តីពី
# សាលាមធ្យមសិក្សាទាំង១៥២ គ្រោងជាប់សាលារៀនគំរូ
# ឆ្នាំសិក្សា ២០២៣ - ២០២៤

## ១- សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងអនុវត្តកំណែទម្រង់សាលារៀនយ៉ាងសកម្ម តាមរយៈការដាក់ឱ្យអនុវត្តស្តង់ដាសាលារៀនគំរូនៅកម្រិតមធ្យមសិក្សា ក្នុងគោលបំណងពង្រឹងស្វ័យគ្រប់គ្រងសាលាមធ្យមសិក្សា និងផ្តល់សេវាអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន ប្រសិទ្ធភាព ដើម្បីផ្តល់ឱកាសឱ្យសិស្សានុសិស្សមានបំណិនខ្ពស់សម្រាប់ជីវិត និងការងារ និងត្រៀមរួចជាស្រេចបន្តការសិក្សានៅកម្រិតឧត្តមសិក្សាឬចូលក្នុងទីផ្សារការងារ។ ជាមួយនេះដែរ ក៏មានរបាយការណ៍លទ្ធផល នៃការចុះជួយគាំទ្រសាលាមធ្យមសិក្សាគោលដៅ ១៥២ ដែលបង្ហាញឱ្យឃើញពីបញ្ហាប្រឈម និងដំណោះស្រាយ សម្រាប់ផ្តល់ជូនដល់ក្រុមការងារជួយគាំទ្រសាលារៀនអនុវត្តស្តង់ដាសាលាមធ្យមសិក្សាគំរូ នៅថ្នាក់តំបន់ទាំង៥ ដើម្បីយកជាមូលដ្ឋាន ក្នុងការចុះជួយសាលារៀនគោលដៅឱ្យចំបញ្ហា និងឆ្លើយតបបាននឹងតម្រូវការជាក់ស្តែងរបស់សាលារៀន។

ក្នុងឆ្នាំសិក្សា២០២៣-២០២៤ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ បានរៀបចំប្រព័ន្ធស្វ័យវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ ដែលបានដាក់បញ្ចូលស្តង់ដា៥ ដែលមានសូចនាករ៨២ សម្រាប់អនុវិទ្យាល័យ និងមានសូចនាករ៨៣ សម្រាប់វិទ្យាល័យ។ សាលារៀនមធ្យមសិក្សា១៥២ គ្រោងជាប់ស្តង់ដាសាលាមធ្យមសិក្សាគំរូឆ្នាំ២០២៤ ដែលក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការជ្រើសរើសពីដើមឆ្នាំសិក្សាកន្លងមក បានចូលរួមធ្វើស្វ័យវាយតម្លៃតាមប្រព័ន្ធអនឡាញ Google Form ដោយសាលារៀនផ្ទាល់ ក្នុងនោះអនុវិទ្យាល័យ ១៣ និងវិទ្យាល័យ ១៣៩ ។

## ២- សកម្មភាពអន្តរាគមន៍តាមសាលាគោលដៅ

ចាប់ពីដើមឆ្នាំ២០២៤ ក្រុមការងារចុះជួយគាំទ្រការអនុវត្តសាលារៀនមធ្យមសិក្សាសាធារណៈគំរូ តំបន់ទាំង៥ ដែលមានសមាសភាពនៅក្នុងអង្គភាពនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ បានប្រជុំពិភាក្សា និងរៀបចំផែនការសកម្មភាពចុះជួយសាលារៀនគោលដៅ ដោយផ្អែកលើព្រឹត្តិបត្រព័ត៌មានសាលារៀន និងស្វ័យវាយតម្លៃសាលារៀន។ ជាមួយនេះ ក្រុមការងារតាមតំបន់នីមួយៗបានពិភាក្សាជាមួយសាលារៀនគោលដៅ ដើម្បីរៀបចំផែនការចុះគាំទ្រឱ្យបានច្បាស់លាស់ និងចំគោលដៅបញ្ហាប្រឈមរបស់សាលានីមួយៗ។ ដោយឡែក សកម្មភាពគាំទ្រសំខាន់ៗ ចុះជួយតាមសាលាគោលដៅ រួមមាន៖

- ការប្រមូលសិស្សចូលរៀន
- ឆ្លុះបញ្ចាំងការអនុវត្តតេស្តស្តង់ដា ដើមឆ្នាំសម្រាប់ធ្វើផែនការ បង្រៀន និងផែនការសិក្សារៀនសូត្រ
- របៀបគណនាពិន្ទុវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា
- ឆ្លុះបញ្ចាំងកិច្ចព្រមព្រៀងលទ្ធផលការងារ (គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងបុគ្គលិកអប់រំ)
- គាំទ្រ និងជំរុញ ដំណើរការ (បន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ និងបណ្ណាល័យ)
- ពង្រឹងការបង្រៀន និងរៀន ដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្ស
- ដឹកនាំពិភាក្សាការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា (សេចក្តីណែនាំលេខ ២៩ អយក.សណន)
- លើកទឹកចិត្តសាលារៀនដែលមានធនធានគ្រូបង្រៀន និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ឱ្យអនុវត្តការរៀនពេញមួយថ្ងៃ
- ពន្យល់ និងបកស្រាយសូចនាករដែលមានពិន្ទុក្រោមស្តង់ដា (ក្រោមពិន្ទុ ៣)
- រកសកម្មភាពគាំទ្របន្ថែម (គ្រូ និងសិស្ស) ដើម្បីជួយបង្កើនលទ្ធផលសិក្សារបស់សិស្ស

- បានពិនិត្យ និងរៀបចំក្របខណ្ឌកម្មវិធីចំណាយលើការអនុវត្តផែនការសកម្មភាពលម្អិតចុះគាំទ្រស្តង់ដាសាលាមធ្យមសិក្សាគំរូ ឆ្នាំ២០២៤។

សកម្មភាពអន្តរាគមន៍ រួមមាន ៖

- រៀបចំជា ៥តំបន់ មានបំណែងចែកតួនាទី និងភារកិច្ចប្រចាំខេត្តគោលដៅ តាមតំបន់នីមួយៗច្បាស់លាស់ តាមរយៈលិខិតបង្គាប់ការផ្ទៃក្នុងនាយកដ្ឋាន.មចទ
- រៀបចំផែនការសកម្មភាពជួយគាំទ្រតាមសាលារៀននីមួយៗ ឆ្ពោះទៅសម្រេចបានស្តង់ដាសាលារៀនគំរូ សម្រាប់សាលាគោលដៅទាំងអស់ ដោយផ្អែកលើមូលដ្ឋានស្វ័យវាយតម្លៃរបស់សាលារៀន និងមន្ទីរអប់រំ
- ការរៀបចំគណកម្មការគ្រប់គ្រងសាលារៀន
- ការប្រជុំក្រុមបច្ចេកទេស និងថ្នាក់និទស្សន៍
- ការធ្វើតេស្តស្តង់ដានៅតាមសាលារៀន ត្រូវអនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងលេខ ៣៤
- សាលារៀនត្រូវធ្វើស្វ័យវាយតម្លៃសាលារៀនប្រចាំឆមាស ដើម្បីអាចមើលឃើញការប្រែប្រួលនៃការអនុវត្តស្តង់ដាសាលារៀនគំរូ។ មួយវិញទៀត ក្រុមការងារតំបន់បានពង្រឹងការអនុវត្តសកម្មភាពក្រៅម៉ោងសិក្សា និងការរៀបចំបំប៉នសិស្សរៀនយឺត
- សហការជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត នៅរាល់ពេលចុះធ្វើការជាមួយសាលារៀន
- នៅក្នុងខែសីហា ២០២៤ នេះ ក្រុមការងារនិងសាលារៀន ផ្តោតនិងជំរុញការអនុវត្តការជួយសិស្សថ្នាក់ទី៩ និងទី១២ សម្រាប់ត្រៀមប្រឡងសញ្ញាបត្រនៅចុងឆ្នាំនេះ ក្នុងគោលបំណងឱ្យទទួលបានលទ្ធផលសិក្សាខ្ពស់ជាងមុន ពិសេសការទទួលបានការជាប់ស្តង់ដាសាលារៀនគំរូ។

## ៣- លទ្ធផលសម្រេចបានរបស់សាលារៀន

រូបភាព ៣.១. ស្ថិតិសាលារៀនគោលដៅទាំង ១៥២ អនុវត្តម៉ោងបង្រៀននិងរៀន ក្នុងឆ្នាំសិក្សា ២០២៣-២០២៤




តាមប្រព័ន្ធឌីជីថលប្រមូលទិន្នន័យរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ សាលារៀនបានផ្តល់ទិន្នន័យដោយផ្ទាល់ក្នុងប្រព័ន្ធ។ សាលារៀន ១៣ ស្មើ ៨.៥៥ភាគរយ បានអនុវត្តម៉ោងបង្រៀននិងរៀនតិចជាង ៣០ម៉ោង ខណៈដែលសាលារៀន ១០១ ស្មើ ៦៦.៣៥ភាគរយ បានអនុវត្តម៉ោងបង្រៀននិងរៀនចន្លោះពី ៣០ម៉ោង ដល់ ៣៤ម៉ោង។ ជាមួយគ្នានោះដែរ សាលារៀនដែលបានអនុវត្តម៉ោងបន្ថែមតាមសេចក្តីណែនាំលេខ២៩ អយក.សណន ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ ចំនួន ២៦ ស្មើ ១៧.១១ភាគរយ ដោយផ្តោតលើសកម្មភាព១៥ រួមមាន ៖ សរសេរតាមអាននិងតែងសេចក្តី គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ប្រវត្តិវិទ្យា និងភាសាបរទេស, ការអប់រំឌីជីថល, អំណានក្នុងបណ្ណាល័យ, ពង្រឹកការសរសេរតាមអាន តែងសេចក្តី គណិតវិទ្យា និងវិទ្យាសាស្ត្រ, ការស្រាវជ្រាវគម្រោង, ការរៀបចំសិស្សឱ្យស្វ័យសិក្សា ក្លឹបសិក្សា, ជួយសិស្សរៀនយឺត, ការរៀបចំកម្មវិធីទស្សនកិច្ច

សិក្សា, ការងារស្ម័គ្រចិត្តនិងអភិវឌ្ឍបំណិនទន់, ការអប់រំតាមបែបសាសនា, ការអប់រំចំរិយាធម៌, ការអប់រំសុខភាព, ប្រឹក្សាអាជីព, បំណិនជីវិតតាមមូលដ្ឋាន, និងកម្មវិធីអភិវឌ្ឍយុវជន។ សាលារៀន ១២ ស្មើ ៧.៨៩ភាគរយ បានអនុវត្តការបង្រៀននិងរៀនពេញមួយថ្ងៃ មានរំលេចដូចមាននៅក្នុងសេចក្តីណែនាំលេខ៥៥ អយក.សណន ស្តីពីដំណើរការគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈឆ្នាំសិក្សា២០២៤-២០២៥។ សាលារៀនដែលបានអនុវត្តម៉ោងបង្រៀន និងរៀន ពីរវេនមាន ៤៩ សាលារៀន ស្មើ ៣២.២៤ភាគរយ និងសាលារៀនដែលអនុវត្តម៉ោងបង្រៀន និងរៀន មួយវេន មាន ១០៣ សាលារៀន ស្មើ ៦៧.៧៦ភាគរយ។

**រូបភាព ៣.២** ស្ថិតិសាលារៀនគោលដៅទាំង ១៥២ ទទួលបានលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិខ្ពស់ជាងថ្នាក់ជាតិ ភាគរយABCខ្ពស់ជាង៤០ភាគរយ និងស្វ័យវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូបានពិន្ទុខ្ពស់ជាង ២៤៩ ពិន្ទុ




សាលារៀនគោលដៅទាំង១៥២ ដែលមានសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ១៣៨ ក្នុងនោះមានសាលារៀន ៩៨ ស្មើ ៧១.០១ភាគរយ ដែលទទួលបានភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ៨ តុលា ២០២៤ ខ្ពស់ជាងថ្នាក់ជាតិ(៧៩ភាគរយ)។ បន្ថែមពីនេះ សាលារៀនដែលទទួលបានភាគរយសិស្សប្រឡងជាប់ ABC ខ្ពស់ជាង ៤០ភាគរយ នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ១០ សាលារៀន ស្មើ ៧.២៥ភាគរយ។ សាលារៀនបានធ្វើស្វ័យវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ តាមប្រព័ន្ធឌីជីថលរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មានសាលារៀន ១២៥ ស្មើ ៨២.២៤ភាគរយ ទទួលបានពិន្ទុជាប់ស្តង់ដាអប្បរមា ១០៩សាលារៀន ស្មើ ៧១.៧១ភាគរយ និងសាលារៀនជាប់ស្តង់ដា១៦ ស្មើ ១០.៥៣ភាគរយ។

## ៤- បញ្ហាប្រឈម

ជាមួយនឹងលទ្ធផលដែលសាលារៀនគោលដៅទាំង១៥២ សម្រេចបាន សាលារៀនក៏ជួបនូវបញ្ហាប្រឈមមួយចំនួនដូចជា ៖

- កត្តាចំណេះដឹងផ្នែកបច្ចេកវិទ្យា និងសាលារៀន៖ (១) ខ្វះអគារសិក្សា និងខ្វះគ្រូមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រ និង(២)ការប្រើបច្ចេកវិទ្យាឌីជីថលសម្រាប់ដំណើរការបង្រៀន និងរៀននៅមានកម្រិតដោយខ្វះសម្ភារឌីជីថល និងសេវាអ៊ីនធើណែតខ្សោយពិបាកក្នុងការរៀននិងបង្រៀន។
- កត្តាសិស្ស គ្រួសារ និងសហគមន៍៖ (១) ឪពុកម្តាយឬអាណាព្យាបាលសិស្សមួយចំនួនមិនសូវសហការជាមួយគ្រូ និងមិនសូវជម្រុញកូនចៅឱ្យចូលរៀន (២)សិស្សមួយចំនួនមិនទាន់ចេះប្រើ និងមិនមានសម្ភារបច្ចេកទេសគាំទ្រសម្រាប់រៀនគ្រប់គ្រាន់ (៣)មាតាបិតា ឬអាណាព្យាបាល អាជ្ញាធរ និងសហគមន៍មិនសូវជួយជំរុញសិស្សឱ្យមានស្វ័យសិក្សាបន្ថែមពីម៉ោងរៀននៅសាលារៀន និង(៤)សិស្សមួយចំនួនតូចអវត្តមានច្រើនព្រោះរវល់ជួយរកចំណូលជួយដល់ឪពុកម្តាយ។

## ៥- វិធានការដោះស្រាយ

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ សាលារៀនបាន៖

- កត្តាចំណេះដឹងផ្នែកបច្ចេកវិទ្យា និងសាលារៀន៖ (១)សាលារៀនបានដំណើរការបង្រៀននិងរៀនជាពីរវេន និងបានស្នើសុំគ្រូពីសាលារៀននៅតំបន់ក្បែរគ្នាជួយ ឬសាលារៀនបានបើថ្នាក់បង្រៀនតាមអនឡាញចំពោះមុខវិជ្ជាដែលខ្វះគ្រូដូចជាសាលារៀននៅខេត្តព្រះសីហនុ និងរតនៈគីរីជាដើម (៣)បណ្តុះបណ្តាលពីការប្រើប្រាស់កម្មវិធីគាំទ្រក្នុងការរៀនបន្ថែមតាមប្រព័ន្ធអនឡាញ (៤)បែងចែកសិស្សជាក្រុមតូចៗ ដើម្បីមកយកសន្លឹកកិច្ចការពីគ្រូទៅរៀន និងបានដាក់កិច្ចការឱ្យសិស្សធ្វើជាប្រចាំ និង (៥) គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា បានប្រើប្រាស់កម្មវិធីICT ក្នុងការដំណើរការបង្រៀន និងរៀន។
- កត្តាសិស្ស គ្រួសារ និងសហគមន៍៖ (១)លោកគ្រូអ្នកគ្រូព្យាយាមពន្យល់ និងលើកទឹកចិត្តសិស្សឡើងវិញ (២)សាលារៀនព្យាយាមទំនាក់ទំនងជាមួយមាតាបិតាសិស្សក្នុងកាជម្រុញនិងលើកទឹកកូនៗ និងពន្យល់ពីសារសំខាន់នៃចំណេះដឹង (៣)គណៈគ្រប់គ្រងលោកគ្រូអ្នកគ្រូបានផ្សព្វផ្សាយដល់សិស្ស ឪពុកម្តាយ អាណាព្យាបាល អាជ្ញាធរដែនដីដើម្បីឱ្យសិស្សបានចូលរៀន (៤)សាលារៀនព្យាយាមពន្យល់ពីអត្ថប្រយោជន៍នៃការសិក្សាតាមអនឡាញដល់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្ស ដើម្បីឱ្យពួកគាត់ផ្តល់ឱកាសរៀនដល់កូន និងចូលរួមជួយជំរុញការសិក្សារបស់កូន (៥)ជួយបំប៉នគ្រូ និងសិស្ស ដែលមិនទាន់ចេះប្រើប្រាស់កម្មវិធីបង្រៀន និងរៀនតាមអនឡាញឱ្យចេះ (៦)ចុះជួយពន្យល់ដល់សិស្ស និងមាតាបិតាសិស្ស ដើម្បីផ្តល់ឱកាសឱ្យបានចូលរៀនពេញលេញ (៧)ព្យាយាមណែនាំសិស្សក្នុងការប្រើប្រាស់សម្ភារនានាដើម្បីងាយស្រួលស្វ័យសិក្សាបន្ថែម និង(៨)សាលារៀន និងអាជ្ញាធរដែនដីបានចូលរួមក្នុងការណែនាំដល់អាណាព្យាបាលសិស្សឱ្យយល់ពីគុណសម្បត្តិពីការសិក្សារៀនសូត្រនៅផ្ទះរបស់កូនចៅរបស់គាត់។

## ៦- ទិសដៅបន្ត

ក្រោមការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា ដែលមាននាយកដ្ឋានជំនាញជាសេនាធិការ សាលារៀនគោលដៅទាំង ១៥២ បានបន្តដាក់ទិសដៅ ៖

- ផ្សព្វផ្សាយ និងណែនាំដល់អាណាព្យាបាលសិស្ស សហគមន៍ អាជ្ញាធរ និងអ្នកពាក់ព័ន្ធឱ្យបានយល់ពីការសិក្សា និងមានការគាំទ្រឱ្យមានភាពប្រសើរ
- ជំរុញលោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងស្វ័យសិក្សាអំពីបច្ចេកវិទ្យា ឬបំណិនឌីជីថល និងបណ្តុះបណ្តាលដល់លោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្សក្នុងប្រើប្រាស់ឱ្យស្របទៅតាមបរិបទថ្មី ដើម្បីបម្រើឱ្យការសិក្សាពីចម្ងាយមានប្រសិទ្ធភាព
- ជំរុញការលើកកម្ពស់សមត្ថភាពគ្រូបង្រៀនក្នុងការជានានិរន្តរភាពការងារបង្រៀននិងរៀន និងទំនាក់ទំនងល្អជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន សហគមន៍ សប្បុរសជន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ សំដៅអភិវឌ្ឍន៍សាលារៀនឱ្យមានភាពរីកចម្រើននាថ្ងៃអនាគត
- ពង្រឹងនិយ័តភាពការបង្រៀន និងរៀន ការបាត់ម៉ោងសិក្សាក្រៅផ្លូវការ ដើម្បីជានាដល់ការបញ្ចប់កម្មវិធីសិក្សា គ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់នៅដំណាច់ឆ្នាំសិក្សា តាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បន្តអធិការកិច្ចផ្ទៃក្នុងលើការងារបច្ចេកទេស ការងារគ្រប់គ្រងរដ្ឋបាល ការប្រើប្រាស់ថវិកា កម្មវិធីការកែលម្អបរិស្ថានសាលារៀនលើការងារអាហារូបករណ៍
- បន្តអនុវត្តការងារផ្នែកបំណិនជីវិត ដើម្បីធានាបាននូវការផ្សារភ្ជាប់ទ្រឹស្តី និងការអនុវត្តជាក់ស្តែងឱ្យសិស្សទទួលបំណិនពិតប្រាកដសម្រាប់ជាជំនួយក្នុងជីវភាពរស់នៅប្រចាំថ្ងៃ
- ពង្រឹងការប្រជុំក្រុមបច្ចេកទេស ការអនុវត្តវិធីសាស្ត្របង្រៀន ការផលិត និងការប្រើប្រាស់សម្ភារឧបទេស
- ជំរុញឱ្យមានសកម្មភាពបណ្ណាល័យ និងបន្ទប់ពិសោធន៍
- បន្តពង្រឹងកិច្ចសហការជាមួយអង្គការជាដៃគូអភិវឌ្ឍ សប្បុរសជននានា ដើម្បីរួមចំណែកក្នុងការលើកកម្ពស់គុណភាពបង្រៀន និងរៀនការរួមគ្នាកាត់បន្ថយការបោះបង់ការសិក្សារបស់សិស្ស

## ៧- សេចក្ដីសន្និដ្ឋាន

ការផ្ដល់ទិន្នន័យរបស់សាលារៀនគោលដៅ១៥២ តាមប្រព័ន្ធប្រមូលទិន្នន័យរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងតាមរយៈការចុះបង្វឹក និងជួយគាំទ្រពីមន្ត្រីនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅកន្លងមកជាលទ្ធផល សាលារៀនគោលដៅ ១៥២ សម្រេចបានពិន្ទុជាប់ស្តង់ដា ១២៥ ស្មើ ៨២.២៤ភាគរយ ជាប់ស្តង់ដាអប្បរមា ១០៩ ស្មើ ៧១.៧១ភាគរយ និងសាលារៀនជាប់ស្តង់ដា១៦ ស្មើ ១០.៥៣ភាគរយ។ ទោះបីមានវឌ្ឍនៈភាពល្អយ៉ាងនេះក៏ដោយ ក៏សាលារៀនមួយចំនួននៅជួបបញ្ហាប្រឈមខ្លះៗដែលមិនទាន់អាចអនុវត្តបាន ៖ មិនទាន់មានបន្ទប់រៀនឌីជីថលគ្រប់សាលារៀន ការពង្រីកការបង្រៀននិងរៀនពេញមួយថ្ងៃ ការអនុវត្តការបង្រៀនក្រៅម៉ោងបន្ថែម ដែលមិនទាន់ឆ្លើយតបទៅនឹងសហគមន៍សាលារៀន។ ជាមួយគ្នានោះដែរ ទោះបីជាសាលារៀន ១៥២ មានសាលារៀនមួយចំនួនមានពិន្ទុមិនជាប់ស្តង់ដាសាលាមធ្យមសិក្សាគំរូ នៅចុងឆ្នាំសិក្សា ២០២៣-២០២៤ ក៏ក្រុមការងារនៅតែបន្តការចុះជួយគាំទ្រទៅតាមផែនការដែលបានគ្រោងទុក ហើយសង្ឃឹមថានៅឆ្នាំសិក្សាខាងមុខនិងបានជាសាលាមានស្តង់ដាតាមការចង់បានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ថ្ងៃចន្ទ ៨រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០២៤
អ្នកធ្វើរបាយការណ៍

យឹម វណ្ណៈ

**បានឃើញ និងឯកភាព**
**ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ**

**ជា ខុម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អគ្គនាយកដ្ឋានអប់រំ
នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

# បញ្ជីឈ្មោះសាលារៀនមធ្យមសិក្សាគោលដៅទាំង១៥២
# សម្រាប់វាយតម្លៃជាសាលាមធ្យមសិក្សាគំរូ ក្នុងឆ្នាំសិក្សា ២០២៣-២០២៤

| ល.រ | | អាគតដ្ឋាន | ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | | ពិន្ទុស្វ័យវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ ២០២៤ | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | ភាគរយប្រឡងជាប់ | ភាគរយ ABC | ស្តង់ដាទី១ | ស្តង់ដាទី២ | ស្តង់ដាទី៣ | ស្តង់ដាទី៤ | ស្តង់ដាទី៥ | ពិន្ទុសរុប |
| បន្ទាយមានជ័យ | | | | | | | | | | |
| 1 | 1 | វិ.ភ្នំធំ | 84.72% | 31.60% | 63 | 115 | 27 | 94 | 14 | 313 |
| 2 | 2 | វិ.សម្តេចឪ (បជ) | 85.22% | 29.56% | 41 | 60 | 13 | 62 | 7 | 183 |
| 3 | 3 | វិ.សិរីសោភ័ណ | 91.51% | 36.79% | 62 | 78 | 16 | 81 | 13 | 250 |
| 4 | 4 | វិ.ហស ខ្លាកូន (ធនធាន) | 95.57% | 41.87% | 67 | 113 | 21 | 79 | 7 | 287 |
| 5 | 5 | វិ.សកពន អូរអំបិល | 80.31% | 21.44% | 67 | 107 | 24 | 93 | 15 | 306 |
| 6 | 6 | វិ.ប៉ោយប៉ែតក្រុង(ធនធាន) | 79.33% | 13.33% | 61 | 95 | 13 | 82 | 13 | 264 |
| 7 | 7 | វិ.ជប់វារី (ធនធាន) | 80.59% | 21.52% | 64 | 93 | 16 | 74 | 11 | 258 |
| បាត់ដំបង | | | | | | | | | | |
| 8 | 1 | វិ.សតជ ហស សំពៅលូន | 86.74% | 34.85% | 65 | 75 | 17 | 49 | 15 | 221 |
| 9 | 2 | វិ.ហស ត្រែង | 86.52% | 13.48% | 73 | 111 | 25 | 97 | 16 | 322 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 10 | 3 | វិ.សំឡូត | 77.25% | 16.77% | 70 | 115 | 29 | 108 | 20 | 342 |
| 11 | 4 | វិ.ហស ភ្នំសំពៅ(ធនធាន) | 79.31% | 29.31% | 71 | 98 | 17 | 99 | 14 | 299 |
| 12 | 5 | វិ.បវេល (ធនធាន) | 72.90% | 20.99% | 61 | 87 | 20 | 94 | 13 | 275 |
| 13 | 6 | វិ.សម្តេចឪ (បប) | 75.44% | 28.32% | 89 | 122 | 19 | 81 | 12 | 323 |
| 14 | 7 | វិ.ស ខេង កន្ទឺ២ | 85.86% | 21.21% | 69 | 97 | 21 | 91 | 15 | 293 |
| 15 | 8 | វិ.ជ្រៃ | 84.86% | 35.68% | 43 | 56 | 7 | 28 | 2 | 136 |
| 16 | 9 | វិ.ល្វា | 93.65% | 38.10% | 77 | 133 | 30 | 98 | 13 | 351 |
| 17 | 10 | វិ.ស្រុកឯកភ្នំ | 82.53% | 25.28% | 5 | 5 | 5 | 5 | 5 | 25 |
| 18 | 11 | វិ.មោងឫស្សី | 72.35% | 22.06% | 56 | 91 | 21 | 74 | 12 | 254 |
| កំពង់ចាម | | | | | | | | | | |
| 19 | 1 | វិ.ឈើនលានហាន់ជ័យ | 68.79% | 21.99% | 67 | 83 | 17 | 71 | 12 | 250 |
| 20 | 2 | វិ.មេសជ្រៃ | 83.75% | 35.63% | 45 | 87 | 14 | 68 | 11 | 225 |
| 21 | 3 | វិ.ហស មានជ័យ | 78.69% | 27.87% | 62 | 94 | 15 | 75 | 11 | 257 |
| 22 | 4 | វិ.ព្រែកដំបូក | 78.72% | 21.28% | 102 | 144 | 30 | 115 | 20 | 411 |
| 23 | 5 | វិ.សម្តេចជួនណាត | 85.83% | 27.17% | 72 | 81 | 16 | 85 | 9 | 263 |
| 24 | 6 | វិ.ហស ខ្ចៅ | 93.17% | 33.79% | 72 | 106 | 25 | 99 | 18 | 320 |
| 25 | 7 | វិ.ហស ស្គន់ | 83.52% | 28.69% | 76 | 118 | 18 | 88 | 19 | 319 |
| 26 | 8 | វិ.ហស ពាមជីកង | 84.36% | 30.73% | 102 | 132 | 29 | 111 | 19 | 393 |
| កំពង់ឆ្នាំង | | | | | | | | | | |
| 27 | 1 | អនុវិ. ក្រាំងស្គារ | | | 56 | 105 | 21 | 77 | 14 | 273 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 28 | 2 | វិ.មខជ សាមគ្គីមានជ័យ | 86.11% | 38.89% | 80 | 116 | 22 | 98 | 20 | 336 |
| 29 | 3 | វិ.ទួលខ្ពស់ | 87.90% | 25.00% | 74 | 81 | 15 | 69 | 5 | 244 |
| 30 | 4 | វិ.ព្រះបាទសុរាម្រឹត | 69.98% | 22.12% | 56 | 95 | 17 | 79 | 9 | 256 |
| 31 | 5 | វិ.ហស បរិបូណ៌ | 59.15% | 19.10% | 60 | 109 | 15 | 87 | 12 | 283 |
| 32 | 6 | វិ.បរន ហស រលាប្អៀរ | 82.35% | 27.55% | 79 | 118 | 22 | 90 | 17 | 326 |
| 33 | 7 | វិ.បរិបូណ៌ត្បូង | 70.72% | 16.02% | 59 | 97 | 22 | 80 | 13 | 271 |
| កំពង់ស្ពឺ | | | | | | | | | | |
| 34 | 1 | វិ.ហស ចំបក់ | 84.32% | 27.12% | 66 | 84 | 15 | 77 | 11 | 253 |
| 35 | 2 | វិ.ស្លាបលែង | 79.89% | 16.67% | 63 | 84 | 22 | 86 | 15 | 270 |
| 36 | 3 | វិ.បនហស ចាន់ថ្ងាល | 73.96% | 22.57% | 52 | 92 | 22 | 87 | 14 | 267 |
| 37 | 4 | អនុ. អង្គសាយ | | | 79 | 105 | 27 | 80 | 19 | 310 |
| កំពង់ធំ | | | | | | | | | | |
| 38 | 1 | វិ.ហស សណ្ដាន់ | 82.56% | 26.15% | 29 | 44 | 9 | 50 | 6 | 138 |
| 39 | 2 | វិ.ហស តាំងគោក | 87.95% | 27.31% | 85 | 130 | 27 | 103 | 20 | 365 |
| 40 | 3 | វិ.កំពង់ធំ | 82.28% | 27.38% | 59 | 82 | 22 | 95 | 20 | 278 |
| 41 | 4 | វិ.ហស បល្ល័ង្គ | 85.37% | 20.33% | 58 | 125 | 22 | 91 | 20 | 316 |
| 42 | 5 | វិ.កំពង់ថ្ម | 90.52% | 31.03% | 67 | 100 | 17 | 74 | 12 | 270 |
| 43 | 6 | វិ.ហស ក្រវ៉ា | 96.60% | 43.40% | 80 | 118 | 18 | 95 | 19 | 330 |
| 44 | 7 | វិ.តាំងក្រសាំង | 82.41% | 14.83% | 82 | 98 | 24 | 76 | 14 | 294 |
| កំពត | | | | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 45 | 1 | វិ.ចប ព្រះរាជសម្ភារ | 88.78% | 34.69% | 72 | 76 | 18 | 77 | 14 | 257 |
| 46 | 2 | វិ.ព្រៃឃ្លៃ | 78.13% | 25.00% | 58 | 79 | 15 | 60 | 7 | 219 |
| 47 | 3 | វិ.ព្រះនរោត្តមសីហមុនី | 96.88% | 54.69% | 66 | 107 | 18 | 74 | 13 | 278 |
| 48 | 4 | វិ.ព្រះបិតាជាតិ | 82.33% | 30.08% | 17 | 57 | 14 | 5 | 8 | 101 |
| 49 | 5 | វិ.មាស សុភាបានៀរ | 90.27% | 33.63% | 40 | 98 | 6 | 70 | 9 | 223 |
| 50 | 6 | វិ.វត្តអង្គរជ័យ | 82.48% | 26.28% | 47 | 101 | 18 | 80 | 13 | 259 |
| 51 | 7 | វិ.មកជ កំពតក្រុង | 83.33% | 29.55% | 60 | 97 | 23 | 83 | 16 | 279 |
| 52 | 8 | វិ.ហស បរិភិស | 88.30% | 36.26% | 51 | 61 | 11 | 60 | 9 | 192 |
| 53 | 9 | វិ.កន្សោមអក | 89.57% | 27.83% | 50 | 95 | 21 | 86 | 10 | 262 |
| កណ្តាល | | | | | | | | | | |
| 54 | 1 | អនុវិ. ហស ព្រែកស្ដី | | | 65 | 105 | 26 | 85 | 15 | 296 |
| 55 | 2 | វិ.ហស កំពង់កន្ទួត | 99.62% | 53.79% | 69 | 100 | 20 | 75 | 14 | 278 |
| 56 | 3 | វិ.ហស អង្គស្នួល | 88.29% | 30.86% | 62 | 73 | 15 | 54 | 10 | 214 |
| 57 | 4 | វិ.សអតហស ព្រែកតាទែន | 81.89% | 22.83% | 80 | 105 | 19 | 81 | 14 | 299 |
| 58 | 5 | វិ.ហស សំពៅពូន | 80.75% | 25.82% | 100 | 118 | 24 | 92 | 17 | 351 |
| 59 | 6 | វិ.ហស កោះធំ | 69.44% | 24.60% | 51 | 96 | 19 | 84 | 15 | 265 |
| 60 | 7 | វិ.ទេពប្រណម្យ | 78.69% | 26.23% | 47 | 100 | 14 | 88 | 16 | 265 |
| 61 | 8 | វិ.ហស ស្អាង | 74.20% | 22.28% | 69 | 106 | 18 | 101 | 13 | 307 |
| 62 | 9 | វិ.ពុកឫស្សី | | | 72 | 112 | 27 | 98 | 18 | 327 |
| កោះកុង | | | | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 63 | 1 | វិ.ថ្មស | 91.89% | 39.19% | 43 | 49 | 50 | 56 | 29 | 227 |
| 64 | 2 | វិ.ចប តេជោសែន កោះកុង | 75.07% | 20.16% | 75 | 108 | 21 | 91 | 13 | 308 |
| 65 | 3 | វិ.ប៉ាក់ខ្លង | 86.05% | 39.53% | 67 | 103 | 19 | 96 | 15 | 300 |
| 66 | 4 | វិ.ស្រែអំបិល | 82.84% | 24.51% | 60 | 123 | 20 | 96 | 16 | 315 |
| ក្រចេះ | | | | | | | | | | |
| 67 | 1 | វិ.សណ្ដាន់ | 89.00% | 31.00% | 64 | 89 | 19 | 71 | 15 | 258 |
| 68 | 2 | វិ.ខូវ ប៊ុនស៊ុន ក្រចេះក្រុង | 83.52% | 32.95% | 55 | 88 | 20 | 77 | 11 | 251 |
| 69 | 3 | វិ.សតជ ហស ក្រុងក្រចេះ | 72.78% | 29.75% | 73 | 92 | 18 | 75 | 12 | 270 |
| 70 | 4 | អនុវិ. បឹងវែ | | | 83 | 118 | 26 | 89 | 20 | 336 |
| មណ្ឌលគិរី | | | | | | | | | | |
| 71 | 1 | វិ.ហស មណ្ឌលគិរី | 96.48% | 34.67% | 51 | 85 | 19 | 72 | 9 | 236 |
| 72 | 2 | វិ.ហស កែវសីមា | 99.26% | 46.67% | 61 | 113 | 18 | 86 | 13 | 291 |
| ភ្នំពេញ | | | | | | | | | | |
| 73 | 1 | វិ.ហស ពញាពន់ | 80.60% | 13.43% | 10 | 32 | 7 | 4 | 4 | 57 |
| 74 | 2 | អនុវិ. ដង្កោ | | | 64 | 87 | 18 | 69 | 12 | 250 |
| 75 | 3 | វិ.បាក់ទូក | 61.58% | 19.34% | 50 | 57 | 14 | 61 | 7 | 189 |
| 76 | 4 | វិ.ហស បូរី១០០ខ្នង | 75.42% | 25.42% | 65 | 76 | 16 | 88 | 10 | 255 |
| 77 | 5 | វិ.បឹងប្រិយ៍ | 83.47% | 33.88% | 64 | 88 | 19 | 71 | 13 | 255 |
| 78 | 6 | វិ.ឫស្សីកែវ | 61.15% | 16.07% | 47 | 80 | 16 | 68 | 12 | 223 |
| 79 | 7 | វិ.ជស ជ្រោយចង្វារ | 65.29% | 19.41% | 71 | 97 | 24 | 96 | 13 | 301 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 80 | 8 | វិ.ទួលទំពូង | 67.76% | 25.47% | 39 | 48 | 48 | 50 | 27 | 212 |
| 81 | 9 | វិ.សហសបរេន.ច្បារអំពៅ | 63.57% | 14.57% | 43 | 99 | 15 | 84 | 9 | 250 |
| 82 | 10 | អនុវិ. ចតុមុខ | | | 68 | 114 | 21 | 92 | 14 | 309 |
| 83 | 11 | វិ.បឹងត្របែក | 76.12% | 22.39% | 33 | 61 | 10 | 70 | 7 | 181 |
| ព្រះវិហារ | | | | | | | | | | |
| 84 | 1 | វិ.សង្គមថ្មី | 95.74% | 43.26% | 54 | 82 | 17 | 64 | 15 | 232 |
| 85 | 2 | វិ.រវៀង | 88.70% | 25.10% | 65 | 123 | 24 | 96 | 17 | 325 |
| 86 | 3 | វិ.កំពង់ស្រឡៅ | 100% | 32.00% | 96 | 119 | 27 | 99 | 20 | 361 |
| 87 | 4 | វិ.រក្សា | 100% | 62.96% | 52 | 89 | 18 | 79 | 18 | 256 |
| ព្រៃវែង | | | | | | | | | | |
| 88 | 1 | វិ.ហស តាគោក | 72.25% | 22.01% | 69 | 107 | 25 | 95 | 19 | 315 |
| 89 | 2 | វិ.សតជ ហស កំពង់ត្របែក | 79.73% | 26.58% | 56 | 77 | 11 | 87 | 18 | 249 |
| 90 | 3 | វិ.ព្រៃដើមថ្នឹង | 95.72% | 46.69% | 64 | 87 | 16 | 74 | 8 | 249 |
| 91 | 4 | វិ.ហស កំពង់ពពិល | 97.00% | 46.44% | 63 | 104 | 22 | 74 | 16 | 279 |
| 92 | 5 | វិ.ហស ព្រែកសណ្ដែក | 78.93% | 30.00% | 67 | 98 | 23 | 85 | 12 | 285 |
| 93 | 6 | វិ.ព្រះអង្គឌួង | 75.63% | 22.53% | 73 | 116 | 13 | 57 | 16 | 275 |
| 94 | 7 | វិ.ហស កំពង់លាវ | 80.65% | 18.71% | 88 | 135 | 25 | 96 | 20 | 364 |
| 95 | 8 | វិ.ហស ពាមរក៍ | 77.29% | 27.13% | 71 | 112 | 23 | 79 | 17 | 302 |
| 96 | 9 | វិ.ហស ពោធិ៍រៀង | 90.96% | 31.64% | 64 | 113 | 22 | 64 | 14 | 277 |
| ពោធិ៍សាត់ | | | | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 97 | 1 | វិ.តាលោ | 94.55% | 33.64% | 74 | 101 | 20 | 88 | 16 | 299 |
| 98 | 2 | វិ.ហស ១០មករា | 75.00% | 13.71% | 64 | 109 | 22 | 81 | 13 | 289 |
| 99 | 3 | វិ.បាកាន | 80.15% | 25.74% | 83 | 106 | 20 | 94 | 19 | 322 |
| 100 | 4 | វិ.ហស ភ្នំក្រវាញ | 76.57% | 19.25% | 59 | 91 | 21 | 66 | 12 | 249 |
| 101 | 5 | វិ.ហស ក្រគរ | 84.03% | 20.14% | 71 | 120 | 21 | 98 | 17 | 327 |
| 102 | 6 | វិ.ពោធិ៍សាត់ | 55.34% | 17.86% | 71 | 139 | 30 | 113 | 20 | 373 |
| រតនគិរី | | | | | | | | | | |
| 103 | 1 | វិ.បរកែវ | 98.96% | 28.13% | 63 | 114 | 23 | 98 | 14 | 312 |
| 104 | 2 | វិ.អន្តេវាសិកដ្ឋានក្រុងបានលុង | 95.28% | 25.47% | 66 | 123 | 25 | 102 | 18 | 334 |
| 105 | 3 | វិ.ហស ភូមិថ្មី | 84.48% | 25.29% | 63 | 88 | 16 | 70 | 12 | 249 |
| សៀមរាប | | | | | | | | | | |
| 106 | 1 | វិ.ក្រឡាញ់ | 90.20% | 38.94% | | | | | 346 | 346 |
| 107 | 2 | វិ.កំពង់ក្ដី | 92.51% | 39.86% | 53 | 65 | 9 | 42 | 5 | 174 |
| 108 | 3 | វិ.សម្ដេចឪ (សរ) | 86.79% | 26.88% | 47 | 37 | 11 | 38 | 8 | 141 |
| 109 | 4 | វិ.ហស សៀមរាប | 83.21% | 29.39% | 58 | 74 | 18 | 77 | 11 | 238 |
| 110 | 5 | វិ.២៨ មករា | 95.00% | 30.00% | 77 | 97 | 16 | 81 | 9 | 280 |
| 111 | 6 | វិ.សំរោង | 88.93% | 22.13% | 63 | 72 | 15 | 71 | 13 | 234 |
| 112 | 7 | អនុវិ. បាគងម៉ូតវ៉ានី | | | 63 | 87 | 18 | 69 | 12 | 249 |
| 113 | 8 | អនុវិ. អារញ្ញរង្សី | | | 69 | 129 | 23 | 103 | 19 | 343 |
| ព្រះសីហនុ | | | | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 114 | 1 | វិ.ហស មិត្តភាព | 87.68% | 33.65% | 62 | 122 | 27 | 100 | 17 | 328 |
| 115 | 2 | វិ.ហស កែវផុស | 100% | 48.00% | 77 | 99 | 17 | 89 | 13 | 295 |
| 116 | 3 | វិ.ហស ព្រៃនប់ | 84.62% | 31.20% | 67 | 95 | 18 | 83 | 13 | 276 |
| ស្ទឹងត្រែង | | | | | | | | | | |
| 117 | 1 | វិ.សេសានសុវត្ថិភាព | 100% | 35.00% | 57 | 92 | 19 | 88 | 17 | 273 |
| 118 | 2 | អនុវិ. ថាឡាបរិវ៉ាត់ | | | 64 | 100 | 100 | 99 | 18 | 381 |
| 119 | 3 | វិ.ព្រះរាជបូជនីយកិច្ច | 88.09% | 21.94% | 52 | 85 | 15 | 77 | 11 | 240 |
| 120 | 4 | វិ.ហស ស្ទឹងត្រែង | 84.41% | 26.34% | 81 | 119 | 23 | 87 | 20 | 330 |
| 121 | 5 | វិ.ព្រះគោ | 84.27% | 22.47% | 57 | 100 | 18 | 81 | 17 | 273 |
| ស្វាយរៀង | | | | | | | | | | |
| 122 | 1 | វិ.បាវិត | 67.16% | 11.94% | 55 | 84 | 11 | 59 | 11 | 220 |
| 123 | 2 | វិ.ហស ក្រោលគោ | 77.84% | 19.16% | 71 | 91 | 18 | 83 | 12 | 275 |
| 124 | 3 | វិ.គោកព្រីង | 76.47% | 27.45% | 86 | 138 | 25 | 105 | 19 | 373 |
| 125 | 4 | វិ.ហស កំពង់ចក | 74.30% | 24.77% | 64 | 89 | 23 | 67 | 14 | 257 |
| 126 | 5 | វិ.មិត្តភាព ក វ ព្រះពន្លា | 90.91% | 31.82% | 63 | 98 | 16 | 78 | 13 | 268 |
| 127 | 6 | អនុវិ. ឈើទាល | | | 60 | 87 | 13 | 69 | 12 | 241 |
| 128 | 7 | អនុវិ. អណ្តូងពោធិ៍ | | | 63 | 81 | 22 | 79 | 17 | 262 |
| តាកែវ | | | | | | | | | | |
| 129 | 1 | វិ.បវនហស ស្លារមេ | 92.61% | 34.66% | 73 | 115 | 24 | 93 | 14 | 319 |
| 130 | 2 | វិ.សអ ថ្នល់បំបែក | 90.40% | 33.20% | 74 | 105 | 21 | 80 | 14 | 294 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 131 | 3 | វិ.សអ ត្រាំខ្នារ | 83.89% | 33.18% | 74 | 104 | 22 | 83 | 16 | 299 |
| 132 | 4 | វិ.សអ ទន្លេបាទី | 91.30% | 33.54% | 77 | 99 | 24 | 77 | 14 | 291 |
| 133 | 5 | វិ.សអ ព្រៃមេលង | 84.53% | 22.10% | 55 | 103 | 24 | 69 | 15 | 266 |
| 134 | 6 | វិ.សអ ក្ដីទន្ទឹម | 74.86% | 24.58% | 73 | 81 | 18 | 62 | 15 | 249 |
| 135 | 7 | វិ.សអ សំពោង | 90.68% | 32.92% | 68 | 111 | 22 | 85 | 14 | 300 |
| 136 | 8 | វិ.ជស តាកែវ | 80.72% | 23.20% | 72 | 114 | 18 | 85 | 14 | 303 |
| 137 | 9 | វិ.សកពន អង្គរនោប | 89.27% | 20.98% | 51 | 91 | 20 | 89 | 12 | 263 |
| 138 | 10 | វិ.ហស ស្លាគូ | 91.09% | 30.69% | 72 | 116 | 26 | 95 | 16 | 325 |
| 139 | 11 | វិ.សំពោងពន្លៃ | 76.47% | 17.65% | 73 | 100 | 18 | 80 | 16 | 287 |
| កែប | | | | | | | | | | |
| 140 | 1 | វិ.ហស ចំការដូង | 92.12% | 30.91% | 58 | 114 | 23 | 85 | 15 | 295 |
| ប៉ៃលិន | | | | | | | | | | |
| 141 | 1 | វិ.ហស សាលាក្រៅ | 81.87% | 20.47% | 47 | 96 | 18 | 93 | 16 | 270 |
| ឧត្តរមានជ័យ | | | | | | | | | | |
| 142 | 1 | វិ.អំពិល | 98.28% | 22.41% | 69 | 111 | 21 | 99 | 16 | 316 |
| 143 | 2 | វិ.ហស ត្រពាំងប្រាសាទ | 77.33% | 20.33% | 19 | 62 | 20 | 4 | 15 | 120 |
| 144 | 3 | អនុវិ. ហស ត្រពាំងប្រីយ៍ | | | 72 | 107 | 20 | 96 | 15 | 310 |
| 145 | 4 | វិ.ហស ចុងកាល់ | 100% | 22.83% | 74 | 123 | 23 | 90 | 16 | 326 |
| 146 | 5 | វិ.តេជោសែន សំពោង | 93.66% | 24.65% | 64 | 97 | 18 | 88 | 17 | 284 |
| 147 | 6 | វិ.អន្លង់វែង | 87.57% | 22.25% | 68 | 115 | 18 | 74 | 13 | 288 |

| ត្បូងឃ្មុំ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 148 | 1 | វិ.ក្រូចឆ្មារ | 94.70% | 25.17% | 69 | 106 | 16 | 71 | 15 | 277 |
| 149 | 2 | វិ.ហស អូរាំងឪ | 89.86% | 34.10% | 59 | 107 | 13 | 82 | 12 | 273 |
| 150 | 3 | វិ.ហស ត្រពាំងឫស្សី | 78.09% | 27.92% | 46 | 84 | 19 | 66 | 13 | 228 |
| 151 | 4 | វិ.សតហស សួង | 69.69% | 21.81% | 63 | 87 | 18 | 69 | 12 | 249 |
| 152 | 5 | អនុវិ. ហស ទួល សូភី | | | 58 | 81 | 19 | 72 | 13 | 243 |

ថ្ងៃចន្ទ ៨រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ពស ២៥៦៨
ត្រូវនឹងថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤
អ្នកធ្វើរបាយការណ៍

យឹម វណ្ណៈ

បានឃើញ និងឯកភាព
ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ជា ទុធ